SAMAKY
MICROFINANCE
គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
Microfinance Institution

# សាមគ្គី

## ម៉ាយក្រូហ្វាយនែន
## អ៊ីនស៊ីធ្យូសិន ភីអិលស៊ី

SAMAKY MICROFINANCE
INSTITUTION PLC.

**របាយការណ៍ប្រចាំឆ្នាំ២០២០**

# មាតិកា


ស្ថានភាពទូទៅរបស់គ្រឹះស្ថាន........1
ទស្សនៈវិស័យ បេសកម្ម និង គុណតំលៃ........1
សាររបស់ភាគទុនិក........4
សាររបស់ប្រធានក្រុមប្រឹក្សាភិបាល........5
ផលិតផលនិងសេវាកម្ម........8
របាយការណ៍របស់ក្រុមប្រឹក្សាភិបាល........9
របាយការណ៍របស់សវនកម្មឯករាជ្យ........12
តារាងតុល្យការនាការិយបរិច្ឆេទចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០........15
របាយការណ៍លទ្ធផលពេញលេញ សំរាប់ការិយបរិច្ឆេទពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០........16
របាយការណ៍បំរែបំរួលមូលធន........17
របាយការណ៍បំរែបំរួលសាច់ប្រាក់........18
មូលដ្ឋានគ្រឹះនៃការរៀបចំ........19
ទីតាំងរបស់គ្រឹះស្ថាន........21
អាសយដ្ឋានទំនាក់ទំនង........22

# ស្ថានភាពទូទៅរបស់គ្រឹះស្ថាន

## ប្រវត្តិសាមគ្គី

ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ តម្រូវឲ្យប្រជាជនមានមុខរបរ ប្រកបអាជីវកម្មជាលក្ខណៈ គ្រួសារ ឬជាសហគ្រាសធុនតូច និងមធ្យមទៅតាមសមត្ថភាព បច្ចេកទេស និងបទពិសោធន៍ របស់ប្រជាជន។ ដោយសារប្រជាជនជួបផលលំបាក ក្នុងការស្វែងរកប្រភពទុនដើម្បីប្រកបអាជីវកម្មរបស់ខ្លួន បានធ្វើឲ្យភាគទុនិកទាំងអស់ សហការគ្នាចាប់ផ្ដើមបង្កើតគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សាមគ្គីម៉ាយក្រូហ្វាយនែន ភីអិលស៊ី បានទទួលអាជ្ញាប័ណ្ណលេខៈ ម.ហ-៦០ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០១៥ របស់ធនាគារជាតិនៃកម្ពុជា និងបានចុះបញ្ជីពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកំរិត ដែលមានវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម លេខៈ Co.1051KH/2015 ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៥ និងមាន ដើមទុនចុះបញ្ជីដំបូង១,០០០,០០០ដុល្លាអាមេរិក។ គ្រឹះស្ថានចាប់ផ្តើមដំណើរការអាជីវកម្មនៅក្នុង ខែ វិច្ឆិកា ឆ្នាំ ២០១៥ ដែលមានទីតាំងស្ថិតនៅផ្ទះលេខ ៨៣AB ផ្លូវ ១៩៨៦ សង្កាត់ ភ្នំពេញថ្មី ខណ្ឌ សែនសុខ រាជធានី ភ្នំពេញ និងមានបុគ្គលិកដំបូងចំនួន១០នាក់។ ហើយពេលបច្ចុប្បន្ននេះក្រុមហ៊ុនមានដើមទុនចុះបញ្ជីរហូតដល់ ២,០០០,០០០ ដុល្លាអាមេរិក និងមានបុគ្គលិកចំនួន ១៥នាក់។

## ឈ្មោះនិងអត្តសញ្ញាណ

សាមគ្គី មានន័យជាភាសាខ្មែរថា "បង្រួបបង្រួម" ការបង្រួបបង្រួមជាកត្តាចម្បងដែលនាំឲ្យ មានភាពរីកចំរើន សេចក្តីសុខ សុវត្ថិភាព ស្នេហភាពនិងសេចក្តីថ្លៃថ្នូរនៅក្នុងសង្គមជាតិទាំងមូល។ អត្តសញ្ញាណរបស់សាមគ្គីត្រូវបាន ចារិកឡើងដោយផ្ទាំងពណ៌ខៀវចាស់ និងពណ៌មាសចាស់នៅផ្នែកខាងក្រោយ រំលេចដោយអក្សរ "ស" ផុសចេញ ពីផ្ទាំងទាំងពីរ ហើយនៅផ្នែកខាងក្រោមនៃនិមិត្តសញ្ញាមានចារិកអក្សរជាភាសាអង់គ្លេស "SAMAKY MICROFINANCE"។ ពណ៌ខៀវចាស់តំណាងឲ្យភាពជាក់លាក់ ពិតប្រាកដនិងជឿជាក់មកលើស្ថាប័ន។ ពណ៌មាសចាស់តំណាងឲ្យ សន្តិភាព និង មាសប្រាក់ដែលទាក់ទងនឹងប្រតិបត្តិការអាជីវកម្មរបស់ស្ថាប័នប្រកបដោយ ភាពជឿជាក់និងដើម្បីឲ្យពួកគាត់ទទួលបាននូវទំនុកចិត្ត។ អក្សរ "ស" តំណាងឲ្យការសហការជាផ្លូវមួយឆ្ពោះទៅរក ភាពរីកចំរើន និង ជឿនលឿនរវាងគ្រឹះស្ថាន និងអតិថិជន ដើម្បីមានភាពចុំរើនរុងរឿងទាំងប្រជាជន និងសង្គមជាតិទាំងមូល។

## ទីផ្សារគោលដៅ

ទីផ្សារគោលដៅរបស់សាមគ្គីគឺជាប្រជាពលរដ្ឋខ្មែរដែលមានបំណងបង្កើតនិងពង្រីកអាជីវកម្មជាលក្ខណៈគ្រួសារ ឬជាសហគ្រាសធុនតូច និងមធ្យមទៅតាមសមត្ថភាព បច្ចេកទេស និងបទពិសោធន៍របស់ប្រជាជនក្នុងគ្រប់វិស័យនៃសេដ្ឋកិច្ចជាតិ។

# ទស្សនៈវិស័យ បេសកម្ម និង គុណតំលៃ

## ទស្សនៈវិស័យ

ទស្សនៈវិស័យរបស់គ្រឹះស្ថានយើងខ្ញុំគឺក្នុងគោលបំណងធ្វើឲ្យប្រជាពលរដ្ឋកម្ពុជាមានជីវភាពកាន់តែប្រសើរឡើងនៅក្នុងសង្គម។

## បេសកម្ម

ផ្តល់ឱកាសដល់ប្រជាជនទូទៅឲ្យសម្រេចបាននូវបំណងប្រាថ្នាព្រមទាំងជួយដល់អ្នកដែលមានបំណងបង្កើតមុខរបរឲ្យជោគជ័យ តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយ ប្រសិទ្ធិភាព និង និរន្តរភាព។

## គុណតំលៃ

បំរើសេវាកម្មលក្ខណៈងាយស្រួល និងរហ័សទាន់ចិត្តបំផុតជូនអតិថិជន។

ភាពស្មោះត្រង់ និងការទទួលខុសត្រូវចំពោះតួនាទី។

ភាពច្នៃប្រឌិត ដើម្បីការរីកចំរើន។

សុជីវធម៌ដើម្បីសេចក្តីថ្លៃថ្នូរក្នុងសង្គម។






VANS
adidas

## សាររបស់ភាគទុនិក

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សាមគ្គី ភីអិលស៊ី** បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីឆ្លើយតមសេចក្តីត្រូវការរបស់ អតិថិជន ក៏ដូចជាសាធារណៈជនផងដែរនូវទីផ្សារផលិតផលនិងសេវាកម្ម។ នៅក្នុងឆ្នាំ២០២០នេះដែរ យើងជាភាគទុនិកទាំងអស់ បានសង្កេតឃើញថា ស្ទើរតែគ្រប់ស្ថាប័ន ធនាគារ និង ហិរញ្ញវត្ថុ មានការធ្លាក់ចុះ ដោយសារការទទួលរងនូវផលប៉ះពាល់នូវជម្ងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ កូវីដ១៩ ដែលធ្វើឲ្យស្ថាប័នមិនអាចធ្វើប្រតិបត្តិការដូចធម្មតាបាន។

យើងខ្ញុំជាភាគទុនិទាំងអស់គ្នា សង្ឃឹមថានៅឆ្នាំ២០២១ខាងនេះ នឹងបានប្រសើរ និង មានស្ថិរភាពហិរញ្ញវត្ថុដូចធម្មតាឡើងវិញ ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្ររបស់អតិថិជន។

តាងនាមឲ្យភាគទុនិកទាំងអស់ ខ្ញុំសូមអរគុណដល់មន្ត្រីធនាគារជាតិនៃកម្ពុជា មន្ទីរ ក្រសួងនានាដែលពាក់ព័ន្ធ ព្រមទាំងក្រុមប្រឹក្សាភិបាល ថ្នាក់គ្រប់គ្រង និងបុគ្គលិកសាមគ្គី ទាំងអស់ដែលបានខិតខំប្រឹងប្រែង ជួយដល់គ្រឹះស្ថានក្នុងគ្រាលំបាកនេះ។

## សាររបស់ប្រធានក្រុមប្រឹក្សាភិបាល



នៅក្នុងឆ្នាំ២០២០នេះ ប្រទេសកម្ពុជាទាំងមូលបានប្រឈមមុខទៅនឹងជម្ងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរគឺកូវីឌ១៩ ដែលជះឥទ្ធិពលស្ទើរតែគ្រប់វិស័យ ដែលធ្វើឲ្យគ្រឹះស្ថានមានការលំបាកក្នុងការពង្រីកខ្លួនចូលទៅក្នុងទីផ្សារ និងមានការធ្លាក់ចុះនូវប្រតិបត្តិការឥណទាន ១៧,២០%ប្រសិនបើធៀបទៅនឹងឆ្នាំ២០១៩។ បច្ចុប្បន្នគ្រឹះស្ថាននៅតែបន្តធ្លាក់ចុះនូវប្រតិបត្តិការឥណទានទៅឲ្យអតិថិជនក៍ដូចជាសាធារណៈជន ផងដែរ ដោយសារប្រទេសកម្ពុជា បាន និង កំពុងរាតត្បាតនូវជម្ងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ រហូតដល់មានការបិទខ្ទប់នៅតាមតំបន់មួយចំនួន និង អាជីវកម្ម។

សំរាប់ឆ្នាំ២០២១ខាងមុខនេះ យើងសង្ឃឹមថា ជម្ងឺកូវីឌ១៩ នឹងចប់ ហើយប្រទេសទាំងមូលនឹងមានសុវត្ថិភាព និង ស្ថិរភាពហិរញ្ញវត្ថុ ព្រមទាំងអាចបន្តប្រតិបត្តិការដូចធម្មតា ។

ទីបញ្ចប់ខ្ញុំសូមឲ្យបុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់ ខិតខំប្រឹងប្រែង ដើម្បីជួយគ្រឹះស្ថានឲ្យទទួលបានជោគជ័យនាពេលខាងមុខ។

# ក្រុមប្រឹក្សាភិបាល



ឧកញ៉ា ឆាយ សេងអៀង
ប្រធានក្រុមប្រឹក្សាភិបាល



លោកស្រី ឆាយ ចាន់ណា
សមាជិកក្រុមប្រឹក្សាភិបាល



លោក ជុង ចិត្តា
សមាជិកក្រុមប្រឹក្សាភិបាល



លោកជំទាវ ង៉ោ ងួនធារី
សមាជិកក្រុមប្រឹក្សាភិបាល

# រចនាសម្ព័ន្ធគ្រប់គ្រង




ឥណទាន
ពាណិជ្ជកម្ម
ផលិតផល/
សេវាកម្មរបស់
សាមគ្គី
ឥណទាន
ប្រើប្រាស់
ឥណទាន
បុគ្គលិក
ឥណទាន
និយោជិត

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមបង្ហាញរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល រួមជាមួយរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើ សវនកម្មរួចរបស់ក្រុមហ៊ុន នាការិយបរិច្ឆេទ និង ចុងការិយបរិច្ឆេទបញ្ចប់ត្រឹម ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០។

## ក្រុមប្រឹក្សាភិបាល

សមាសភាពនៃក្រុមប្រឹក្សាភិបាលដែលបានបម្រើការងារក្នុងកំឡុងឆ្នាំហិរញ្ញវត្ថុ និងរហូតដល់ចុងកាលបរិច្ឆេទនៃរបាយការណ៍នេះមានដូចខាងក្រោម:

| | |
|---|---|
| លោក ឆាយ សេងអៀង | ប្រធានក្រុមប្រឹក្សាភិបាល |
| លោកស្រី ង៉ោ ងួនធារី | អភិបាល |
| លោកស្រី ឆាយ ចាន់ណា | អភិបាល |
| លោក ជុង ចិត្តា | អភិបាល |

## ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលជាអ្នកទទួលខុសត្រូវដើម្បីធានាថារបាយការណ៍ហិរញ្ញវត្ថុផ្តល់នូវទិដ្ឋភាពពិត និង ត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាចុងការិយបរិច្ឆេទថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ និងលទ្ធផលនៃប្រតិបត្តិការហើយ និង លំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនតំរូវអោយ៖

ក) អនុម័តគោលនយោបាយគណនេយ្យសមស្របទៅតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជាសម្រាប់សហគ្រាសធុនតូចនិង មធ្យម ("CIFRS សម្រាប់សហគ្រាសធុនតូចនិងមធ្យម") ដែលតំរូវអោយមានការវិនិច្ឆ័យ និង ការប៉ាន់ស្មានដោយសមហេតុផល ហើយបន្ទាប់មកត្រូវអនុវត្តគោល នយោបាយ ទាំងនោះជាអចិន្ត្រៃយ៍

ខ) អនុវត្តតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសំរាប់សហគ្រាសធុនតូច និង មធ្យម ឬប្រសិនបើមានគំលាតពីស្តង់ដារទាំងនេះដែលជាប្រយោជន៍ដល់ការបង្ហាញនូវភាពពិត និងត្រឹមត្រូវរបស់របាយការណ៍ហិរញ្ញវត្ថុ គំលាតទាំងនោះត្រូវបានបង្ហាញ ពន្យល់អោយបានច្បាស់លាស់ និងកំណត់ ចំនួនជាទឹកប្រាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ

គ) រក្សាទុកនូវបញ្ជីការគណនេយ្យអោយបានត្រឹមត្រូវ និង ធានាការគ្រប់គ្រងផ្ទៃក្នុងអោយមានប្រសិទ្ធិភាព។

ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុផ្អែកលើមូលដ្ឋាននិរន្តភាពនៃ ដំណើរការអាជីវកម្មលើកលែងតែក្នុងករណី ដែលមានការសន្មត់ថាក្រុមហ៊ុននឹងមិនបន្តប្រតិបត្តិការនៅអនាគតដ៏ខ្លីនិង

ង) បង្កើតគោលនយោបាយទូទៅសំរាប់ក្រុមហ៊ុន អនុម័តរាល់ការសំរេចចិត្ត និង សកម្មភាពទាំងឡាយរបស់ ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនដែលមានផលប៉ះពាល់ជាសារវ័ន្តលើប្រតិបត្តិការអាជីវកម្ម និង លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនហើយ ត្រូវធានាថាគោលនយោបាយ និង ការសំរេចចិត្តទាំងអស់នោះត្រូវបានឆ្លុះបញ្ចាំង យ៉ាងពិតប្រាកដក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនបានធានាអះអាងថាក្រុមហ៊ុនបានអនុវត្តន៍ទៅតាម លក្ខខ័ណ្ឌចាំបាច់នានា ដូចដែលបានបញ្ជាក់ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

តាមគំនិតរបស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានបង្កើតឡើងស្របតាមស្តង់ដារ របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសំរាប់សហគ្រាសធុនតូចនិងមធ្យម ដើម្បីផ្តល់នូវទស្សនៈពិតនិង ត្រឹមត្រូវ ពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០ និងលទ្ធផលនៃប្រតិបត្តិការនិង លំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ចុងការិយបរិច្ឆេទ ។

## ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលបានយកចិត្តទុកដាក់ទៅលើបញ្ហាដូចខាងក្រោម៖

ក) រាល់សារវន្តទាំងអស់ផ្ទេរទៅ ឬពីទុនបំរុង ឬសំវិធានធនក្នុងឆ្នាំហិរញ្ញវត្ថុត្រូវបានបង្ហាញនៅក្នុងរបាយ ការណ៍ហិរញ្ញវត្ថុ។

ខ) សំវិធានធនគ្រាប់គ្រាន់សំរាប់ការខាតបង់លើគណនីដែលត្រូវទារ និងទ្រព្យសកម្មបច្ចុប្បន្ន និងទ្រព្យអកម្ម ត្រូវបានអនុវត្តបើសិនបើចាំបាច់។

គ) បំណុលអសារបង់ ត្រូវបានលុបចោល ប្រសិនបើមាន

ឃ) វិធីសាស្ត្រនៃការវាយតំលៃទ្រព្យសកម្ម ឬបំណុលដែលមានស្រាប់គឺមិនខុសឆ្គងឬមិនសមរម្យ។

ង) មិនមានកាលៈទេសៈណាមួយដែលអាចដឹងពីចំនួនទឹកប្រាក់ណាក៏ដោយ ដែលបានបញ្ជាក់នៅក្នុង របាយការណ៍ហិរញ្ញវត្ថុដែលនាំឱ្យមានការភាន់ច្រឡំ។

ច) មិនមានគំលាតរវាងរបាយការណ៍ហិរញ្ញវត្ថុចុងការិយបរិច្ឆេទ ធៀបនឹង របាយការណ៍ក្នុងកាលបរិច្ឆេទនេះ ដូចជា ធាតុណាមួយ ប្រតិបត្តិការ ឬ ចំនុចសំខាន់ណាមួយដែលមានលក្ខណៈខុសប្រក្រតី ទៅតាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល ដែលនាំអោយប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនសម្រាប់ក្នុងកំឡុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលរបាយការណ៍វាយការណ៍នេះត្រូវបានធ្វើ ឡើង។

ឆ) លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងកំឡុងពេល នៃឆ្នាំហិរញ្ញវត្ថុនេះមិនត្រូវបានទទួលរងផលប៉ះពាល់ដោយជាតុណាមួយ ប្រតិបត្តិការ ឬ ចំនុចសំខាន់ណាមួយដែលមានលក្ខណៈខុសប្រក្រតី។

ជ) គ្មានយថាហេតុ រឺបំណុលផ្សេងទៀតរបស់ក្រុមហ៊ុនបានក្លាយទៅជាប្រតិបត្តិ ឬអាចនឹងត្រូវបានអនុវត្តន៍ក្នុងកំឡុងពេល 12ខែ បន្ទាប់ពីការបញ្ចប់ឆ្នាំហិរញ្ញវត្ថុដែលក្នុងមតិយោបល់របស់ក្រុមប្រឹក្សាភិបាល នឹងមាន ឬអាចប៉ះពាល់ដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលប្រតិបត្តិការនោះដល់ការកំណត់។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលបានភ្ជាប់ជាមួយរបាយការណ៍នេះថាពិតជាបង្ហាញពី ទិដ្ឋភាពពិត និង ត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាចុងការិយបរិច្ឆេទថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ហើយនឹងលទ្ធផលនៃប្រតិបត្តិការ និង លំហូរសាច់ប្រាក់សំរាប់ការិយបរិច្ឆេទបញ្ចប់ទៅតាមស្តង់ដាររហិរញ្ញវត្ថុ អន្តរជាតិនៃកម្ពុជាសំរាប់សហគ្រាសធុនតូច និង មធ្យម។




លោក ឆាយ សេងអៀង
ប្រធានក្រុមប្រឹក្សាភិបាល
ថ្ងៃទី 23 ខែ មេសា ឆ្នាំ 2021

## របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគទុនិកនិងក្រុមប្រឹក្សាភិបាលរបស់ សាមគ្គី មីក្រូហិរញ្ញវត្ថុ អ៊ីនស៊ីធ្យូសិន ភីអិលស៊ី

### ទស្សនៈរបស់សវនករឯករាជ្យ

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ សាមគ្គី ម៉ាយក្រូហ្វាយនែន អ៊ីនស៊ីធ្យូសិន ភីអិលស៊ី ហៅថា (“ក្រុមហ៊ុន”) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ និង របាយការណ៍លទ្ធផលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន និង របាយការណ៍លំហូរសាច់ប្រាក់សំរាប់ការិយបរិច្ឆេទបញ្ចប់ ហើយនឹងគោលការណ៍គណនេយ្យសំខាន់ៗព្រមទាំងកំណត់សម្គាល់ផ្សេងៗ។

តាមទស្សនៈរបស់យើងខ្ញុំរបាយការណ៍ហិរញ្ញវត្ថុនេះបង្ហាញនូវទិដ្ឋភាពពិតប្រាកដ និង ត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការហិរញ្ញវត្ថុហើយនិងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសំរាប់សហគ្រាសធុនតូច និង មធ្យម។

### មូលដ្ឋាននៃទស្សនៈរបស់សវនករ

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិ។ ការទទួលខុសត្រូវរបស់ពួកយើងគឺ ស្ថិតនៅក្រោមស្តង់ដារដែលបានចែង និងរៀបរាប់នៅក្នុងផ្នែកទំនួលខុសត្រូវរបស់សវនករទៅលើរបាយការណ៍ ហិរញ្ញវត្ថុនៃរបាយការណ៍សវនកម្មរបស់ពួកយើង។ យើងជឿជាក់ថាភស្តុតាងសវនកម្ម ដើម្បីពួកយើងប្រមូលបាន គឺគ្រប់គ្រាន់ និង សមហេតុផល ដើម្បីជាមូលដ្ឋានក្នុងការផ្តល់មតិយោបល់របស់យើងខ្ញុំ។

### ទំនួលខុសត្រូវរបស់សវនករឯករាជ្យ និងក្រមសីលធម៌

យើងខ្ញុំជាសវនករឯករាជ្យ ដែលតំរូវអោយអនុលោមតាមក្រមសីលធម៌ ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជា។ ហើយយើងខ្ញុំបានបំពេញនូវរាល់ទំនួលខុសត្រូវនានាដែលតំរូវដោយក្រមសីលធម៌នេះផងដែរ។

#### ព័ត៌មានបន្ថែមទៅលើរបាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍របស់សវនករមានដូចតទៅនេះ

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន គឺជាអ្នកទទួលខុសត្រូវរាល់ព័ត៌មានដែលជាប់ពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុន។ ព័ត៌មាននោះរួមបញ្ចូលទាំងរបាយការណ៍ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនបានរួមបញ្ចូលជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននិងរបាយការណ៍របស់សវនករឡើយ។

ការបញ្ចេញទស្សនៈរបស់ពួកយើងទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គឺមិនបានរាប់បញ្ចូលជាមួយរបាយការណ៍ក្រុមប្រឹក្សាភិបាលឡើយ ហើយពួកយើងក៏មិនបានបង្ហាញជាលិខិតអះអាងទៅលើការសរុបមតិរបស់របាយការណ៍នោះផងដែរ។

ក្នុងការភ្ជាប់គ្នារវាងការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនចំពោះទំនួលខុសត្រូវរបស់សវនករ គឺគ្រាន់តែស្វែងយល់អំពី របាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងទទួលយករបាយការណ៍របស់ពួកគាត់ បើទោះបីជារបាយការណ៍របស់ក្រុមប្រឹក្សាភិបាលមានភាពមិនត្រឹមត្រូវទាក់ទងទៅ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុម ហ៊ុនក៏ដោយ រឺក៏មានភាពមិនប្រក្រតីចំពោះវិជ្ជាជីវៈរបស់សវនករដែលបានធ្វើសវនកម្ម រឺក៏ការកើតឡើងនូវភាពខុសប្រក្រតីណាមួយផ្សេងទៀត។

## ពត៌មានបន្ថែមទៅលើរបាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍របស់សវនករមានដូចតទៅនេះ (តពីទំព័រមុន)

យោងទៅតាមការងារដែលពួកយើងបានបំពេញ ពួកយើងបានសន្និដ្ឋានថា វានឹងមានភាពមិនត្រឹមត្រូវទាក់ទង ជាមួយរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល។ ហេតុដូចនេះហើយទើបបានជាពួកយើងទាមទារនូវរបាយការណ៍ដែលពិតប្រាកដ និងត្រឹមត្រូវ។ យើងខ្ញុំគ្មានអ្វីដែលត្រូវរាយការណ៍ពីបញ្ហានេះទៀតឡើយ។

## ទំនួលខុសត្រូវរបស់អភិបាលទៅលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និង ការបង្ហាញទិដ្ឋភាពពិតប្រាកដនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដោយអនុលោមទៅតាម ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុនៃកម្ពុជាសំរាប់ សហគ្រាសធុនតូច និងមធ្យម និងការណែនាំរបស់ធនាគារជាតិនៃកម្ពុជា។ ក្រុមប្រឹក្សាភិបាលត្រូវទទួលខុសត្រូវដូចគ្នាផងដែរចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលក្រុមប្រឹក្សាភិបាលក្រុមហ៊ុនយល់ថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលពុំមានកំហុសឆ្គងជាសារវ័ន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ត្រូវមានការទទួលខុសត្រូវរាល់សកម្មភាពរបស់ក្រុមហ៊ុនដែលជានាអះអាងថា អាចមានលិទ្ធភាពបន្តក្នុងរយៈពេល១២ខែខាងមុខ និងរាល់បញ្ហាដែលមានជាប់ពាក់ព័ន្ធជាមួយនឹងលិទ្ធភាពអាចបន្តរបស់ក្រុមហ៊ុន និងគោលបំណងដែលអាចធ្វើអោយមានសកម្មភាពនេះកើតឡើង ដែលតម្រូវអោយធ្វើការបង្ហាញទៅជាសាធារណៈដោយសារតែវាមានភាពចាំបាច់។ លើកលែងតែក្រុមប្រឹក្សាភិបាលណាមួយមានបំណងចង់ទូទាត់បំណុលរបស់ក្រុមហ៊ុនទាំងស្រុង រឺក៏អះអាងថានឹងបិទក្រុមហ៊ុន ហើយបើគ្មានសកម្មភាពណាមួយលេចឡើងនោះទេ យើងនៅតែត្រូវការរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដដែល។

## ទំនួលខុសត្រូវរបស់សវនករឯករាជ្យ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទាំងមូល នឹងមិនមានកំហុសឆ្គងជាសារវន្ត មិនថាដោយសារការក្លែងបន្លំ ឬការភាន់ច្រឡំឡើយ។ ហើយ ធ្វើការរាយការរបាយការណ៍សវនករដែលរាប់បញ្ចូលទាំងមតិយោបល់របស់យើងខ្ញុំផងដែរ។ ការធានាអះអាងដែលសមហេតុផល គឺការធានាអះអាងកម្រិតខ្ពស់ ប៉ុន្តែមិនមែនធានាអះអាងថាសវនកម្មដែលធ្វើឡើងស្របតាមស្តង់ដាអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា តែងតែរកឃើញរាល់កំហុសជាសារវន្តនោះឡើយ។ ការបំភាន់អាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានគេចាត់ទុកថាជាសារវន្ត ប្រសិនបើជាលក្ខណៈបុគ្គលឬជាក្រុម ពួកវាអាចជះឥទ្ធិពលដល់ការសម្រេចចិត្តខាងសេដ្ឋកិច្ច របស់អ្នកប្រើប្រាស់ដែលផ្អែកលើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ជាផ្នែកមួយនៃសវនកម្មស្របតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា យើងអនុវត្តការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈ និងរក្សាការសង្ស័យដែលមានជំនាញវិជ្ជាជីវៈ នៅសវនកម្មទាំងមូល។ យើងក៏: -

ក). កំណត់ និងវាយតម្លៃហានិភ័យនៃភាពមិនត្រឹមត្រូវ ខាងសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មិនថាដោយសារការក្លែងបន្លំ ឬកំហុស។ រៀបចំនិងអនុវត្តនីតិវិធីសវនកម្មឆ្លើយតបទៅនឹងហានិភ័យទាំងនោះនិងទទួលបានភស្តុតាងសវនកម្ម ដែលមានលក្ខណៈគ្រប់គ្រាន់នឹងសមស្រប ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់មតិយោបល់របស់យើង។ ហានិភ័យដែលមិនរកឃើញកំហុសខាងសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំគឺមានភាពខ្ពស់ជាងបណ្តាលមកពីកំហុសឆ្គង ព្រោះការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការកែច្នៃ ការលុបចោលដោយចេតនាការ ការបកស្រាយមិនពិត ឬការបំពានក្នុងការគ្រប់គ្រងផ្ទៃក្នុង។

ខ). ទទួលបានការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងសវនកម្មដើម្បីរៀបចំនីតិវិធីសវនកម្ម ដែលសមស្របក្នុងកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងនៃការបញ្ចេញមតិលើប្រសិទ្ធភាពនៃ ការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។

## ទំនួលខុសត្រូវរបស់សវនករឯករាជ្យ (តពីទំព័រមុន)

គ). វាយតំលៃភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើនិងភាពសមហេតុផលនៃ ការប៉ាន់ស្មានគណនេយ្យនិងការបង្ហាញដែលពាក់ព័ន្ធដែលធ្វើឡើងដោយអ្នកគ្រប់គ្រង។

ឃ). សន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់ របស់ក្រុមប្រឹក្សាភិបាលនៃមូលដ្ឋានដែលគួរឱ្យព្រួយបារម្ភនៃគណនេយ្យ និងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានថាតើភាពមិនច្បាស់លាស់នៃសារវន្តមានទាក់ទងនឹងព្រឹត្តិការណ៍ឬលក្ខខណ្ឌដែលអាចធ្វើឱ្យមានការសង្ស័យយ៉ាងខ្លាំងចំពោះសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តភាពអាជីវកម្ម។ ប្រសិនបើយើងសន្និដ្ឋានថាមានភាពមិនច្បាស់លាស់នៃសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលទៅក្នុងរបាយការណ៍របស់សវនកររបស់យើង ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងពត៌មានហិរញ្ញវត្ថុឬបើការលាតត្រដាងពត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិយោបល់សវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍សវនកររបស់យើង។ ទោះយ៉ាងណាព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចបណ្តាលឱ្យក្រុមហ៊ុនបញ្ឈប់និរន្តភាពអាជីវកម្ម។

ង). វាយតំលៃការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមមានការលាតត្រដាងនិងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែល តំណាងឱ្យប្រតិបត្តិការនិងព្រឹត្តិការណ៍មូលដ្ឋានក្នុង លក្ខណៈដែលទទួលបានការបង្ហាញដោយត្រឹមត្រូវ។

យើងបានផ្តល់ពត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចស្តីពីបញ្ហាផ្សេងៗ វិសាលភាពនិងពេលវេលាដែលបានគ្រោងទុកសម្រាប់ធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀតដែលមានរួមបញ្ចូលទាំង ចំណុចខ្វះខាតក្នុងការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្មរបស់យើង។

## បញ្ហាផ្សេងទៀត

ការធ្វើសវនកម្មរបស់យើងខ្ញុំ គឺក្នុងគោលបំណងបង្ហាញពីទស្សនៈទៅលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ជារូបិយប័ណ្ណ ដុល្លារអាមេរិក។ ការបំលែងរបាយការណ៍ហិរញ្ញវត្ថុពីដុល្លារអាមេរិកទៅជាខ្មែររៀលដោយប្រើអត្រាបិទ និងអត្រាមធ្យមនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ បានបង្ហាញឡើងក្នុងគោលបំណងវិភាគបន្ថែមហើយមិនមែនជាផ្នែកសំខាន់នៃមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុនោះទេ។ ការបំលែងនេះមិនត្រូវបានធ្វើសវនកម្មទៅតាមនីតិវិធីដែលបានអនុវត្តទៅលើរបាយការណ៍ហិរញ្ញវត្ថុនោះទេ ហេតុដូច្នេះយើងខ្ញុំមិនបានបញ្ចេញទស្សនៈណាមួយទៅលើការបំលែងនេះឡើយ។

Crowe (KH) Co., Ltd.

ក្រុមហ៊ុនសួនការគណនេយ្យករជំនាញ

Onn Kien Hoe

អភិបាល

ថ្ងៃ23 ខែមេសា ឆ្នាំ2021

## តារាងតុល្យការនាការិយបរិច្ឆេទចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | កំណត់សំគាល់ | ២០២០ ដុល្លារអាមេរិក | ២០១៩ ដុល្លារអាមេរិក | ២០២០ ខ្មែរពាន់រៀល | ២០១៩ ខ្មែរពាន់រៀល |
|---|---|---|---|---|---|
| ទ្រព្យសកម្ម | | | | | |
| សាច់ប្រាក់ក្នុងដៃ | 5 | 815,087 | 655,959 | 3,297,027 | 2,673,033 |
| សមតុល្យនៅធនាគារនានា | 6 | 7,605 | 7,350 | 30,762 | 29,951 |
| ឥណទាន និង បុរេប្រទាន | 7 | 644,069 | 792,810 | 2,605,259 | 3,230,701 |
| ទ្រព្យសកម្មផ្សេងៗ | 8 | 20,829 | 13,905 | 84,253 | 56,663 |
| ប្រាក់តម្កល់តាមច្បាប់ នៅធនាគារជាតិនៃ កម្ពុជា | 9 | 100,000 | 100,000 | 404,500 | 407,500 |
| គ្រឿងបរិក្ខារ | 10 | 6,364 | 8,193 | 25,742 | 33,386 |
| ទ្រព្យអរូបី | 11 | 35,750 | 40,040 | 144,609 | 163,163 |
| ទ្រព្យសកម្មសរុប | | 1,629,704 | 1,618,257 | 6,592,152 | 6,594,397 |
| បំណុល និង មូលធន | | | | | |
| **បំណុល** | | | | | |
| ទ្រព្យអកម្មផ្សេងៗ | 12 | 13,960 | 8,165 | 56,468 | 33,272 |
| ពន្ធលើប្រាក់ចំណេញត្រូវបង់ | 17 | 114 | 157 | 461 | 640 |
| **បំណុលសរុប** | | 14,074 | 8,322 | 56,929 | 33,912 |
| **មូលធន** | | | | | |
| ដើមទុន | 13 | 2,000,000 | 2,000,000 | 8,000,000 | 8,000,000 |
| ទុនបម្រុងបទប្បញ្ញត្តិ | | 81,447 | - | 329,453 | - |
| ខាតបង្គរ | | (465,817) | (390,065) | (1,876,775) | (1,570,358) |
| លំអៀងពីអត្រាប្តូរប្រាក់ | | - | - | 82,545 | 130,843 |
| **មូលធនសរុប** | | 1,615,630 | 1,609,935 | 6,535,223 | 6,560,485 |
| បំណុល និង មូលធនសរុប | | 1,629,704 | 1,618,257 | 6,592,152 | 6,594,397 |

## របាយការណ៍លទ្ធផលពេញលេញ សំរាប់ការិយបរិច្ឆេទពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ២០១៩ ដុល្លារអាមេរិក | ២០២០ ខ្មែរពាន់រៀល | ២០១៩ ខ្មែរពាន់រៀល |
|---|---|---|---|---|---|
| ចំណូលការប្រាក់ | 14 | 154,887 | 112,197 | 626,518 | 454,622 |
| ចំណេញដុល | | 154,887 | 112,197 | 626,518 | 454,622 |
| ចំណូលផ្សេងៗ | 15 | 16,798 | 13,837 | 67,948 | 56,068 |
| ចំណាយលើប្រាក់ខែបុគ្គលិក | 16 | (101,071) | (125,232) | (408,832) | (507,440) |
| រំលស់លើទ្រព្យរូបី និងអរូបី | | (6,800) | (6,420) | (27,506) | (26,014) |
| ចំណាយលើប្រតិបត្តិការផ្សេងៗ | | (60,982) | (53,106) | (246,673) | (215,186) |
| លទ្ធផលចំណេញ/ ខាត ពីប្រតិបត្តិការមុនសំវិធានធន | | 2,832 | (58,724) | 11,455 | (237,950) |
| សំវិធានធនសំរាប់ឥណទានបាត់បង់ | 7 | 4,503 | (30,536) | 18,215 | (123,732) |
| ចំណេញ/ខាត មុនបង់ពន្ធ | | 7,335 | (89,260) | 29,670 | (361,682) |
| ចំណាយពន្ធលើប្រាក់ចំនេញ | 17 | (1,640) | (1,249) | (6,634) | (5,061) |
| ចំណេញ/ខាតបន្ទាប់ពីបង់ពន្ធ | | 5,695 | (90,509) | 23,036 | (366,743) |

## របាយការណ៍បំរែបំរួលមូលធន

### សំរាប់ការិយបរិច្ឆេទពីថ្ងៃ ៣១ ខែធ្នូ ឆ្នាំ២០

| | កំណត់សម្គាល់ | មូលធន<br>ដុល្លារអាមេរិក | ទុនបម្រុង<br>បទប្បញ្ញត្តិ<br>ដុល្លារអាមេរិក | ខាតបង្គរ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|
| សមតុល្យថ្ងៃទី ១.១.២០១៩ | | 2,000,000 | 16,000 | (315,556) | 1,700,444 |
| ខាតសុទ្ធសំរាប់ការិយបរិច្ឆេទ | | - | - | (90,509) | (90,509) |
| ការផ្ទេរទៅទុនបម្រុង | | - | (16,000) | 16,000 | - |
| សមតុល្យថ្ងៃទី ៣១.១២.២០១៩/១.១.២០២០ | | 2,000,000 | - | (390,065) | 1,609,935 |
| ចំណេញសំរាប់ការិយបរិច្ឆេទ | | - | - | 5,695 | 5,695 |
| ការផ្ទេរទៅទុនបម្រុង | | - | 81,447 | (81,447) | - |
| សមតុល្យថ្ងៃទី ៣១.១២. ២០២០ | | 2,000,000 | 81,447 | (465,817) | 1,615,630 |

| | កំណត់សម្គាល់ | មូលធន<br>ខ្មែរពាន់រៀល | ទុនបម្រុង<br>បទប្បញ្ញត្តិ<br>ខ្មែរពាន់រៀល | ខាតបង្គរ<br>ខ្មែរពាន់រៀល | ទឹកប្រាក់<br>លំអៀងបង្គរ<br>ពីការប្តូរប្រាក់<br>ខ្មែរពាន់រៀល | សរុប<br>ខ្មែរពាន់រៀល |
|---|---|---|---|---|---|---|
| សមតុល្យថ្ងៃទី១.១.២០១៩ | | 8,036,000 | 64,288 | (1,267,903) | - | 6,832,385 |
| ខាតសុទ្ធសំរាប់ការិយបរិច្ឆេទ | | - | - | (366,743) | - | (366,743) |
| ការផ្ទេរទៅទុនបម្រុង | | - | (64,288) | 64,288 | - | - |
| លំអៀងពីអត្រាបម្រែបម្រួលប្រាក់ | | (36,000) | - | - | 130,843 | 94,843 |
| សមតុល្យថ្ងៃទី ៣១.១២.២០១៩/ ១.១.២០២០ | | 8,000,000 | - | (1,570,358) | 130,843 | 6,560,485 |
| ចំណេញសំរាប់ការិយបរិច្ឆេទ | | - | - | 23,036 | - | 23,036 |
| ការផ្ទេរទៅទុនបម្រុង | | - | 329,453 | (329,453) | - | - |
| លំអៀងពីអត្រាបម្រែបម្រួលប្រាក់ | | - | - | - | (48,298) | (48,298) |
| សមតុល្យថ្ងៃទី ៣១.១២.២០២០ | | 8,000,000 | 329,453 | (1,876,775) | 82,545 | 6,535,223 |

## របាយការណ៍បំរែបំរួលសាច់ប្រាក់

សំរាប់ការិយបរិច្ឆេទចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ២០១៩ ដុល្លារអាមេរិក | ២០២០ ខ្មែរពាន់រៀល | ២០១៩ ខ្មែរពាន់រៀល |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ចំណេញ/ខាតមុនបង់ពន្ធ | | 7,335 | (89,260) | 29,670 | (361,682) |
| និយ័តភាព៖ | | | | | |
| សំវិធានធនសំរាប់ឥណទានបាត់បង់ | 7 | (4,503) | 30,536 | (18,215) | 123,732 |
| រំលស់លើគ្រឿងបរិក្ខារ | 10 | 2,510 | 3,560 | 10,153 | 14,425 |
| រំលស់លើទ្រព្យអរូបី | 11 | 4,290 | 2,860 | 17,353 | 11,589 |
| ការលក់គ្រឿងបរិក្ខារ | | 85 | 433 | 344 | 1,755 |
| ខាតមុនបម្រែបម្រួលទុនបង្វិល | | 9,717 | (51,871) | 39,305 | (210,181) |
| ការកើនឡើងនិងការថយចុះនៃ៖ | | | | | |
| - ឥណទាននិងបុរេប្រទាន | | 153,244 | (251,969) | 619,872 | (1,026,774) |
| - ទ្រព្យសកម្មផ្សេង | | (6,924) | 6,892 | (28,008) | 28,085 |
| - បំណុលផ្សេងៗ | | 5,795 | (4,564) | 23,441 | (18,598) |
| **សាច់ប្រាក់ដែលត្រូវបានប្រើក្នុងសកម្មភាពប្រតិបត្តិការ** | | 161,832 | (301,512) | 654,610 | (1,227,468) |
| ពន្ធប្រាក់ចំណេញដែលត្រូវបង់ | | (1,683) | (1,191) | (6,808) | (4,826) |
| **សាច់ប្រាក់ដែលត្រូវបានប្រើក្នុងសកម្មភាពប្រតិបត្តិការសុទ្ធ** | | 160,149 | (302,703) | 647,802 | (1,232,294) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញគ្រឿងបរិក្ខារ | 10 | (766) | (3,535) | (3,099) | (14,406) |
| ការទិញទ្រព្យអរូបី | 11 | - | (42,900) | - | (174,818) |
| **សាច់ប្រាក់សុទ្ធដែលត្រូវបានក្នុងសកម្មភាពវិនិយោគ** | | (766) | (46,435) | (3,099) | (189,224) |
| **ការថយចុះនៃសាច់ប្រាក់សុទ្ធ** | | 159,383 | (349,138) | 644,703 | (1,421,518) |
| **សាច់ប្រាក់នៅដើមការិយបរិច្ឆេទក្នុងឆ្នាំ** | | 663,309 | 1,012,447 | 2,702,984 | 4,068,012 |
| **បម្រែបម្រួលអត្រាប្តូរប្រាក់** | | - | - | (19,898) | 56,490 |
| **សាច់ប្រាក់ចុងគ្រា** | | 822,692 | 663,309 | 3,327,789 | 2,702,984 |
| សាច់ប្រាក់ក្នុងដៃ | | 315,087 | 655,959 | 3,297,027 | 2,673,033 |
| សមតុល្យនៅធនាគារនានា | | 7,605 | 7,350 | 30,762 | 29,951 |
| សាច់ប្រាក់សុទ្ធ និងសាច់ប្រាក់សមមូលសរុប | | 822,692 | 663,309 | 3,327,789 | 2,702,984 |

## មូលដ្ឋានគ្រឹះនៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើងតាមសន្ទតិកម្មថ្លៃដើម និងត្រូវបានកែប្រែដើម្បីដាក់បញ្ចូលមូលដ្ឋានវាយតម្លៃផ្សេងទៀតដែលត្រូវបានបង្ហាញ នៅក្នុងផ្នែកផ្សេងទៀតក្រោមគោលនយោបាយគណនេយ្យសំខាន់ៗ និងអនុលោមទៅតាមបទបញ្ញត្តិទាំងឡាយរបស់ធនាគារជាតិនៃកម្ពុជា និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិរបស់កម្ពុជាសំរាប់សហគ្រាសធុនតូចនិងមធ្យម ")CIFRSs for SMEs") ។

ចំណាត់ថ្នាក់ឥណទាននិងសំវិធានធនសំរាប់ឥណទានជាប់សង្ស័យនិងបាត់បង់

យោងតាមសារាចរថ្មីនិងអំឡុងពេលអន្តរកាល 1 គិតចាប់ពីថ្ងៃទី) ខែធ្នូ ឆ្នាំ 2017 ដល់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2018) ក្រុមហ៊ុនត្រូវធ្វើការគណនាឱនភាពលើឥណទានអាក្រក់ និងជាប់សង្ស័យស្របតាមបទប្បញ្ញត្តិដែលគ្រឹះស្ថានត្រូវបានចាត់ថ្នាក់ជា 5 ថ្នាក់ជាមួយ នឹងអត្រាផ្តល់ដូចខាងក្រោម :

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលផុតកំណត់ | សំវិធានធន |
|---|---|---|
| ១. សំវិធានធនទូទៅ | | |
| ឥណទានរយៈពេលខ្លី(តិចជាង១ឆ្នាំ)ធម្មតា | ពី០ថ្ងៃទៅ១៥ថ្ងៃ | ១% |
| ឥណទានរយៈពេលវែង(ច្រើនជាង១ឆ្នាំ)ធម្មតា | ពី០ថ្ងៃទៅ២៩ថ្ងៃ | ១% |
| ២. សំវិធានធនជាក់លាក់ | | |
| ឥណទានរយៈពេលខ្លី(តិចជាង១ឆ្នាំ) | | |
| បំណុលឃ្លាំមើល | ពី១៥ថ្ងៃទៅ៣០ថ្ងៃ | ៣% |
| ក្រោមស្តង់ដារ | ពី៣១ថ្ងៃទៅ៦០ថ្ងៃ | ២០% |
| សង្ស័យ | ពី៦១ថ្ងៃទៅ៩០ថ្ងៃ | ៥០% |
| បាត់បង់ | ពី៩១ថ្ងៃឡើងទៅ | ១០០% |
| ឥណទានរយៈពេលវែង(ច្រើនជាង១ឆ្នាំ) | | |
| បំណុលឃ្លាំមើល | ពី៣០ថ្ងៃទៅ៨៩ថ្ងៃ | ៣% |
| ក្រោមស្តង់ដារ | ពី៩០ថ្ងៃទៅ១៧៩ថ្ងៃ | ២០% |
| សង្ស័យ | ពី១៨០ថ្ងៃទៅ៣៥៩ថ្ងៃ | ៥០% |
| បាត់បង់ | ពី៣៦០ថ្ងៃឡើងទៅ | ១០០% |

បទប្បញ្ញត្តិដែលត្រូវអនុវត្តត្រូវបានអនុវត្តទៅលើគ្រប់ទីកន្លែង និងក្រៅតារាងតុល្យការ របស់ធនាគារនិង

ស្ថាប័នហិរញ្ញវត្ថុ។

ប្រកាសនេះតម្រូវឱ្យមានការប្រៀបធៀបបទប្បញ្ញត្តិ ស្តីពីការថយចុះតម្លៃដោយផ្អែកលើ CIFRS សំរាប់សហគ្រាសធុនតូចនិងមធ្យម។ ក្នុងករណីបទប្បញ្ញត្តិដែលបានគណនា ស្របតាមប្រកាសមានកម្រិតទាបជាង ការខាតបង់សំវិធានធនដែលបានកំណត់ ដោយផ្អែកលើ CIFRS សំរាប់សហគ្រាសធុនតូចនិងមធ ក្រុមហ៊ុន នឹងទទួលស្គាល់ការ ខាតបង់សំវិធានធនដែលបានកំណត់ស្របតាម CIFRS សំរាប់សហគ្រាសធុនតូចនិងមធ្យម ។ ក្នុងករណីបទប្បញ្ញត្តិខ្ពស់ជាង ការបាត់បង់សំវិធានធន ក្រុមហ៊ុននឹងទទួល ស្គាល់ការបាត់បង់សំវិធានធនដែលបានកំណត់ស្របតាម CIFRS សំរាប់សហគ្រាសធុនតូចនិងមធ្យម និងផ្ទេរភាពខុសគ្នាពីប្រាក់ចំណូលដែលបានរក្សាទុកទៅជាទុនបម្រុងបទប្បញ្ញត្តិ។ក្រុមហ៊ុនបានបង្ហាញនូវទុនបម្រុងបទប្បញ្ញត្តិនៅក្នុង សេចក្តីថ្លែងការណ៍អំពីបម្រែបម្រួលមូលធន ។

| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2020 | | ឥណទាន<br>ដុល្លារអាមេ | សំវិធាន<br>% | បទដ្ឋាន<br>ធនាគារ<br>ដុល្លារអា |
|---|---|---|---|---|
| ១. ឥណទានអាយុក្រោម១ឆ្នាំ | | | | |
| ស្តង់ដារ | | 332,704 | 1% | 3,327 |
| ឃ្លាំមើល | | - | 3% | - |
| ក្រោមស្តង់ដារ | | 85,955 | 20% | 17,191 |
| ជាប់សង្ស័យ | | 667 | 50% | 334 |
| បាត់បង់ | | 111,110 | 100% | 111,110 |
| | ក | 530,436 | | 131,962 |

| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2020<br>២. ឥណទានអាយុលើស១ឆ្នាំ | | ឥណទាន<br>ដុល្លារអាមេ | សំវិធាន<br>% | បទដ្ឋាន<br>ធនាគារ<br>ដុល្លារអា |
|---|---|---|---|---|
| ស្តង់ដារ | | | | |
| ឃ្លាំមើល | | 51,625 | 1% | 516 |
| ក្រោមស្តង់ដារ | | 39,042 | 3% | 1,171 |
| ជាប់សង្ស័យ | | 59,522 | 20% | 11,904 |
| បាត់បង់ | | 55,101 | 50% | 27,551 |
| | | - | 100% | - |
| | ខ | 205,290 | | 41,142 |
| សរុបរួម | ក+ខ | 735,726 | | 173,104 |

## ទីតាំងរបស់គ្រឹះស្ថាន






## អាសយដ្ឋានទំនាក់ទំនង

ផ្ទះលេខ ៨៣AB ផ្លូវ ១៩៨៦ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានី ភ្នំពេញ។

ទូរស័ព្ទលេខ : ០២៣ ៦៦៦ ៥៩ ៥៩

អ៊ីមែល : info@samaky.com.kh

### លេខទូរស័ព្ទទំនាក់ទំនងសំខាន់ៗ

| | |
|---|---|
| ១. រថយន្តសង្គ្រោះបន្ទាន់ | ១១៩ |
| ២. ក្រុមពន្លត់អគ្គីភ័យ | ១១១ |
| ៣. ស្នាក់ការប៉ូលីស | ១១៧ |
| ៤. ប៉ូលីសខ្លាហោះ | ០២៣ ៣៦៦ ៨៤១ |
| ៥. ប៉ូលីសព្រហ្មទណ្ឌ | ០១២ ៩៩៩ ៩៩៩ |
| ៦. ប៉ូលីសចរាចរណ៍ | ០១២ ៩៤២ ៤៨៤ |
| ៧. រថយន្តពន្លត់អគ្គីភ័យ | ០១២ ៧៨៦ ៨៩១ |
| ៨. រថយន្តសង្គ្រោះបន្ទាន់ភ្នំពេញ | ០២៣ ៧២៤ ៨៩១ |
| ៩. ប្រឆាំងការជួញដូរស្ត្រី និងកុមារ | ០២៣ ៩៩៤ ៩៥៥ |